ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

# បច្ចេកទេសដាំដំណាំអំពៅ



រៀបចំដោយ៖ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សហការជាមួយ
នាយកដ្ឋានដំណាំឧស្សាហកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

ឧបត្ថម្ភការបោះពុម្ព ដោយ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០១៧



រក្សាសិទ្ធិគ្រប់យ៉ាង ដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។





**អាសយដ្ឋាន** : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចម្ការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : ០១២ ៧៣ ៥៥ ៩៦/០១៧ ៦២ ២៨ ៤៨

**ទូរសារលេខ** : (៨៥៥)២៣ ២១០ ៩៤៨

Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម - Department of Agricultural Extension

**គេហទំព័រ**: http://www.maff.gov.kh

# សៀវភៅ

# ស្តីពី

# បច្ចេកទេសដាំដំណាំអំពៅ

## រៀបចំដោយ

## នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សហការជាមួយ
## នាយកដ្ឋានដំណាំឧស្សាហកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់

ឧបត្ថម្ភការបោះពុម្ពដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រក្សាសិទ្ធដោយ: នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# សមាសភាពចូលរួមចំណែកផលិតសៀវភៅ ស្តីពីបច្ចេកទេសដាំដំណាំអំពៅ

## I. ទីប្រឹក្សាផ្តល់យោបល់:

| | | |
|---|---|---|
| ១. បណ្ឌិត | **ហ៊ាន វណ្ណហាន** | អគ្គនាយកដ្ឋានកសិកម្ម |
| ២. បណ្ឌិត | **ម៉ៅ មិនា** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៣. លោក | **ប៉ែន វុទ្ធី** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៤. លោក | **គឹម ដារ៉ា** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |

## II. អ្នករៀបរៀង:

| | | |
|---|---|---|
| ១. លោក | **ផាន ទូច** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |

## III. អ្នកស្រាវជ្រាវ:

| | | |
|---|---|---|
| ១. លោក | **លី ចំរើន** | នាយកដ្ឋានដំណាំឧស្សាហកម្ម |

## IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

| | | |
|---|---|---|
| ១. លោក | **លី ចំរើន** | នាយកដ្ឋានដំណាំឧស្សាហកម្ម |
| ២. លោក | **ប៊ឹង សេរីហ៊ុច** | នាយកដ្ឋានដំណាំឧស្សាហកម្ម |
| ៣. លោក | **ហុង ឫទ្ធី** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៤. លោក | **ឈុន សុភ័ក្ត្រ** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |



# មាតិកា

ទំព័រ


១. ស្ថានភាពទូទៅ..........០១

២. លក្ខណៈរូបសាស្ត្រដំណាំអំពៅ..........០២

ក. លក្ខណៈប្រព័ន្ធ ឫស..........០២

ខ. លក្ខណៈដើម..........០២

គ. លក្ខណៈស្លឹក..........០៣

ឃ. លក្ខណៈផ្កា..........០៣

៣. តំបន់ដាំដុះ..........០៤

៤. បរិស្ថានដំណាំអំពៅ..........០៤

៥. បច្ចេកទេសដាំដុះ និងថែរក្សាដំណាំអំពៅ..........០៦

ក. រដូវកាលដាំដុះ..........០៦

ខ. ការរៀបចំដី..........០៧

គ. របៀបដាំ..........០៧

ឃ. ការដាក់ជី..........១២

ង. ការសំអាតស្មៅ..........១៣

៦. ជំងឺ និងសត្វល្អិតចង្រៃ..........១៤

៦.១ សត្វល្អិតចង្រៃ..........១៤

ក. ដង្កូវស៊ីកំពូល និងដើម..........១៤

ខ. រុយស..........១៥

គ. ដង្កូវស៊ីរ៉ូងដើម..........១៦

៦.២ ជំងឺ..........១៦

ក.ជំងឺស្លឹកពណ៌ស..........១៦

ខ. ជំងឺពន្លកស្មៅបៃតង..........១៦

គ. ជំងឺស្នាមប្រឡាក់..........១៧

ឃ. ជំងឺស្រពោនរលួយពណ៌ក្រហម..........១៨

៧.ការប្រមូលផល..........១៩

៨. ការកែច្នៃ..........២១




## ១. ស្ថានភាពទូទៅ

អំពៅជាដំណាំមួយប្រភេទមានដើមកំណើតពីប្រទេសឥណ្ឌា ដែលប្រជាកសិករយើងស្គាល់ស្ទើរគ្រប់គ្នាទាំងអស់ ហើយដំណាំនេះក៏បានដាំដុះលើផ្ទៃដីតូចៗ ស្ទើពាសពេញ នៃព្រះរាជាណាចក្រកម្ពុជាយើងដែរ។

ជាទូទៅប្រជាកសិករតែងនិយមយកអំពៅមកគៀបយកទឹកសម្រាប់ហូបដូចជាភេសជ្ជៈធម្មតា ឬគេនិយមហូបផ្ទាល់តែម្តង។សារៈសំខាន់នៃដំណាំនេះក្នុងប្រទេសយើងក៏ដូចជាក្នុងភិភពលោក គេបានកែច្នៃ ទឹកអំពៅយកទៅធ្វើជាស្កសរ ដែលយើងត្រូវការចាំបាច់ខានមិនបានជារៀងរាល់ថ្ងៃ ទឹកអំពៅ ផ្ទុកទៅដោយ វីតាមីន និង ជាតិខនិជ ដែលជួយការពារជំងឺផ្តាសាយ ក្អក និងឈឺកផងដែរ។

ទឹកអំពៅ មានជាតិផ្អែមខ្ពស់ពីធម្មជាតិវាជាជម្រើសដ៏ល្អមួយ សម្រាប់អ្នកចូលចិត្តផ្អែម ដោយវាបានជួយបំពេញបន្ថែមនូវសារធាតុដែលបាត់បង់ និងកាត់បន្ថយការនឿយហត់ អស់កម្លាំង និងជួយបំពេញបន្ថែមនូវប្រូតេអ៊ីន និង កាត់



បន្ថយកម្តៅក្នុងខ្លួន នៅពេលដែល អ្នកមានជំងឺគ្រុន ជាពិសេស ចំពោះអ្នកកើត ជំងឺលឿងឬថ្លើមប្រភេទ A ឱ្យជាសះស្បើយយ៉ាងឆាប់រហ័ស លើសពីនេះទៀតទឹកអំពៅសម្បូរទៅដោយ សារធាតុប៉ូតាស្យូម ដែលអាចជួយរំលាយអាហារ និងសម្រួលដល់ការទល់លាមកធ្វើឱ្យមុខរបួសឆាប់ជាសះស្បើយ និងពង្រឹងប្រព័ន្ធការពាររាងកាយទៀតផង។

ក្រៅពីសារៈសំខាន់សម្រាប់ធ្វើស្ករអំពៅនៅប្រទេសមួយចំនួនគេបាន

កែច្នៃទឹកអំពៅយកទៅធ្វើជាអាកុល ស្រា និងធ្វើជាចំណីសត្វ ហើយម្យ៉ាងទៀត កាកអំពៅគេបានយកទៅកែច្នៃធ្វើជាក្រដាស់ និងក្តារបន្ទះ ។ល។ ចំពោះប្រទេសកម្ពុជា នាពេលបច្ចុប្បន្ននេះដំណាំអំពៅ គឺគេបានកែច្នៃធ្វើស្ករក្នុងសិប្បកម្មតូចៗប៉ុណ្ណោះក្រៅពីនេះគឺប្រជាកសិករយើងនិយមហូបទឹកអំពៅដូចជាភេជ្ជៈធម្មតាដែរ ។

## ២. លក្ខណៈរូបសាស្ត្រនៃដំណាំអំពៅ

### ក. លក្ខណៈប្រព័ន្ធឫស

ដំណាំអំពៅជាប្រភេទដំណាំគ្មានប្រព័ន្ធឫសកែវ ។



ក្នុងរយៈពេលមួយខែដំបូង ក្រោយពីដាំកូនអំពៅលូតលាត់ អាស្រ័យលើឫសនៃកំណាត់ដើម ។

- ក្រោយពី រយៈពេល៣ខែមក កូនអំពៅស្រូបសារធាតុចិញ្ចឹមពីដើម ហើយឫសជន្លល់ ត្រូវបានដុះចេញពីថ្នាំងនៅជិតគល់ ដើម្បីជួយទប់ដើមកុំឱ្យដួលរលំនៅពេលដែលមានខ្យល់បោកបក់ ។

### ខ. លក្ខណៈដើម

- ដើមអំពៅមានសភាពរឹង គ្មានប្រហោងដែលមានកម្ពស់ពី ១៥០ ស.ម ទៅ ៣៥០ ស.ម ។

- កម្ពស់ដើមប្រែប្រួលទៅតាមពូជ និងលក្ខខណ្ឌដាំដុះ។ ដើមអំពៅមានរាងជាស៊ីឡាំង ឬ បំពង់ហើយមានពណ៌ទៅតាមប្រភេទពូជ ។

- ដើមអំពៅឈរត្រង់ទៅលើ គ្មានបែកមែកលើកលែងតែដើមបែកចេញពីគល់ ។





### គ. លក្ខណៈស្លឹក

- ស្លឹកអំពៅ ស្ថិតនៅត្រង់ថ្នាំងឆ្លាស់គ្នាដែលប្រវែងស្លឹកប្រែប្រួលពី ៦០ស.ម ទៅ ១៣០ ស.ម អាស្រ័យទៅតាមពូជ និងលក្ខខណ្ឌនៃការដាំដុះ
- ស្លឹកអំពៅលូតលាស់ខ្លាំងស្របពេលដែលអំពៅកំពុងលូតលាស់ដើម
- នៅពេលដែលស្លឹកថ្មីលូតលាស់ ស្លឹកចាស់នៅផ្នែកខាងក្រោមប្រែទៅជាស្ងួត ហើយងាប់តែម្តង ។



### ឃ. លក្ខណៈផ្កា

- ផ្កាមានរាងដូចជាកួរ ស្ថិតនៅលើអ័ក្សឈរដែលចេញពីដើមមេ ហើយកួរអាចមានប្រវែងពី ៤០ ស.ម ទៅ ៦០ ស.ម ។

 

## ៣. ដំបន់ដាំដុះ



ជាទូទៅកសិករយើងតែងតែនិយមដាំដុះអំពៅនៅតាមដងទន្លេដូចជានៅខេត្តក្រចេះ កំពង់ចាម កណ្តាល ព្រៃវែង ក្រៅពីតំបន់តាមដងទន្លេគេអាចដាំដំណាំនេះនៅតាមតំបន់ដីខ្ពង់រាប ដីកោះ និងតាមជម្រាលជើងភ្នំ លើដីក្រហម ឬ ដីខ្មៅដូចជានៅតាមខេត្តបាត់ដំបង ស្ទឹងត្រែង មណ្ឌលគីរី រតនគីរី ជាដើម។ល។ បច្ចុប្បន្នកសិករបានធ្វើការដាំដុះនៅតាមស្រែទួលល្បាយខ្សាច់ ដូចជាខេត្តស្វាយរៀង តាកែវ និងកំពង់ស្ពឺ ហើយទទួលបានទិន្នផលយ៉ាងល្អ។

## ៤. បរិស្ថានដំណាំអំពៅ

អំពៅជាដំណាំមួយប្រភេទ ដែលទាមទារកម្តៅខ្លាំងសម្រាប់ការលូតលាស់ដងដើម។ ក្នុងរយៈពេលលូតលាស់ដើម ស្លឹក ដំណាំនេះទាមទារសីតុណ្ហភាពខ្ពស់ជាមធ្យមពី ២៥ ទៅ ៣០អង្សាសេ ក្នុងរយៈពេល២៤ ម៉ោង លើកលែងតែដល់ដំណាក់កាលកំណរកំណើតស្ករគឺពី ២ ទៅ ៣ ខែមុនពេលកាប់ ទើបទាមទារសីតុណ្ហភាពទាបជាមមធ្យមពី ១៨ ទៅ២២ អង្សាសេដើម្បី

អាចបង្កើតជាតិស្ករច្រើន។ អំពៅជាដំណាំដែលចូលចិត្តពន្លឺថ្ងៃ បើពន្លឺថ្ងៃមិនគ្រប់គ្រាន់ធ្វើឱ្យការបែកគុម្ពចុះខ្សោយ។ ដូច្នេះពេលណាពន្លឺថ្ងៃគ្រប់គ្រាន់ គួបផ្សំនឹងការដាក់ជីដំណាំអំពៅឱ្យបានសមស្រប ដើមអំពៅថ្លោស និងស្លឹកធំ។

ដំណាំនេះក៏ជាដំណាំមួយ ដែលត្រូវការទឹកច្រើនគួសមដែរ ដូច្នេះដើម្បីធានាឱ្យបានផលល្អ គឺយើងត្រូវលៃយ៉ាងណាពេលដែលដំណាំស្ថិតក្នុងដំណាក់កាលលូតលាស់ខ្លាំងអាចចំពេលដែលមានភ្លៀងធ្លាក់ច្រើនហើយផ្ទុយទៅវិញប្រមាណជា២ ទៅ ៣ ខែមុនពេលប្រមូលផលអាចចំពេលដែលមានភ្លៀងធ្លាក់តិច ឬស្ទើរតែគ្មានភ្លៀងធ្លាក់ទើបជាការប្រសើរក្នុងការផ្តល់ទិន្នផលស្ករខ្ពស់ អំពៅតម្រូវការទឹកភ្លៀងប្រចាំឆ្នាំប្រមាណពី ១២០០ - ២០០០ ម.ម ក្នុងមួយឆ្នាំ។

ប្រភេទដីដែលល្អសម្រាប់ដំណាំអំពៅគឺដីល្បប់ល្បាយខ្សាច់មិនជាំទឹក ដីជ្រោះទឹក មានជីជាតិល្អ មានស្រទាប់ទី១ ជ្រៅ និងមាន PH ពី ៥,៥–៦,៨។

ចំពោះប្រទេសកម្ពុជាយើង ដីដែលសមស្របសម្រាប់ដំណាំនេះ គឺដីល្បប់ល្បាយខ្សាច់តាមដងទន្លេ ដីក្រហម និងដីខ្មៅតាមតំបន់ខ្ពង់រាប ។

ដំណាំនេះដាំបានល្អនៅលើដីស្រទាប់ទី ១ រាក់ (ជម្រៅស្រទាប់ទី១ រាក់ជាង២០ស.ម) ចំពោះដីដែលមានគ្រួសក្រហមច្រើន នោះមិនសមស្របសម្រាប់ដំណាំនេះឡើយ។



## ៥. បច្ចេកទេសដាំដុះ និងថែទាំដំណាំអំពៅ

### ក. រដូវកាលដាំដុះ

#### ~ តំបន់មាត់ទន្លេ

ជាទូទៅគេអាចចាប់ផ្តើមដាំក្នុងអំឡុងពេលពីខែវិច្ឆិកា ធ្នូ រហូតដល់ចុងខែមករា ហើយប្រមូលផលនៅអំឡុងខែសីហា កញ្ញាមុនពេលទឹកឡើងលិចចម្ការ។ការប្រមូលផលនៅក្នុងអំឡុងខែនេះ ជាទូទៅ គេយកអំពៅសម្រាប់គៀបយកទឹកហូប។ ចំពោះការដាំដុះសម្រាប់ធ្វើស្ករត្រូវប្រមូលផលក្នុងអំឡុងខែវិច្ឆិកា ធ្នូ ឬ មករា គឺចំពេលដែលមានសីតុណ្ហភាពទាប។ ដូច្នេះដំណាំអាចមានអាយុដល់ទៅ ១១ ខែឬ១២ខែ និងអាចដល់ ១៣ខែ ។





#### ~ តំបន់ខ្ពង់រាប

ចំពោះតំបន់នេះគេអាចចាប់ផ្តើមដាំក្នុងអំឡុងខែមេសានិងឧសភាពេលដែលមានភ្លៀងធ្លាក់ដំបូង ហើយគេអាចប្រមូលផលក្នុងអំឡុងខែមករា និងកុម្ភៈ។ ដូច្នេះការប្រមូលផលក្នុងខែនេះដំណាំអាចមានអាយុប្រមាណជា ១០ ខែ។

## ខ. ការរៀបចំដី



ការភ្ជួររាស់ ជាទូទៅចំពោះដំណាំអំពៅក៏ប្រហាក់ប្រហែលទៅនឹងដំណាំចម្ការផ្សេងៗទៀតដែរ។ ការភ្ជួររាស់ធ្វើឡើងក្នុងគោលបំណងដើម្បីជ្រំជ្រួយដីឱ្យផុសល្អ ដែលអាចបង្កឱ្យដំណាំដុះលូតលាស់ឆាប់ម្យ៉ាងទៀត តាមរយៈការរៀបចំដីយើងអាចសម្លាប់ស្មៅចង្រៃ សត្វល្អិត និងជំងឺមួយចំនួន ។ ជាធម្មតាគេអាចភ្ជួរ ២ សារ និងរាស់ជ្រួយដី ២ទៅ ៣ សារ ដើម្បីឱ្យដីផុសល្អ។ លក្ខណៈពិសេសនៃការភ្ជួររាស់ គឺភ្ជួរលើកទី ១ គេធ្វើនៅពេលដែលទឹកស្រកចុះផុតពីចម្ការ ( ចំពោះតំបន់មាត់ទន្លេ ) បន្ទាប់មកគេទុកដីហាលចោល រយៈពេលប្រមាណ ១០ ថ្ងៃ ហើយចាប់ផ្តើមភ្ជួរលើកទី២បន្ទាប់មក ត្រូវរាស់ដីឱ្យបានម៉ត់ល្អ ។ ចំពោះតំបន់ខ្ពង់រាបវិញ គេបានចាប់ផ្តើមភ្ជួរដីលើកទី ១ ប្រមាណជា ១ ទៅ ២ ខែ មុនពេលដាំ ។

បន្ទាប់មកពេលដែលមានភ្លៀងធ្លាក់ល្មម ហើយគេអាចភ្ជួរលើកទី ២ រួចរាស់ឆ្វតរង ឬ កាប់រណ្តៅ និងចាប់ផ្តើមការដាំដុះតែម្តង ។

## គ. របៀបដាំ

ការដាំអំពៅ គេអាចធ្វើបានច្រើនយ៉ាងគឺ គេអាចបណ្តុះកូនជាមុនសិន ឬក៏ដាក់ដាំកំណាត់ដើមដែលមានភ្នែកតែម្តង ។

### ការបណ្តុះកូន

- វិធីនេះគឺគេបណ្តុះកូនជាមុនសិន ទើបយកទៅដាំនៅចម្ការពេល



ដែលកូននោះលាស់បានធំល្មម ( អាយុប្រមាណជា ១ ខែ ) វិធីនេះគេច្រើនអនុវត្តចំពោះការដាំក្នុងរណ្តៅ។

~ ជាដំបូងគេត្រូវកាត់ដើមជាកំណាត់ខ្លីៗ ដែលមានថ្នាំងមួយៗ រួចហើយគេដាក់តម្រៀបគ្នាក្នុងថ្នាលនៅក្បែរប្រភពទឹកដើម្បីងាយស្រួលក្នុងការស្រោចស្រព ។



~ កំណាត់ដើម ក្រោយតម្រៀបគ្នានោះមិនត្រូវលប់ដីឱ្យជិតតែម្តងទេ ហើយត្រូវដាក់ភ្នែក នៅលើដើម្បីបង្ក ភាពងាយស្រួលក្នុងការដុះពន្លក និងដើម្បីឱ្យកាន់តែប្រសើរត្រូវគ្របចំបើងពីលើ ។

~ ជាទូទៅគេត្រូវស្រោចទឹកមួយថ្ងៃម្តង ដើម្បីឱ្យកូនអំពៅនោះលូតលាស់បានល្អ។ ពេលដែលកូនអំពៅមានទំហំដើមប៉ុនម្រាមដៃមានអាយុប្រមាណជា១ ខែទើបគេយកទៅដាំនៅចម្ការ ។

~ ការដាក់ដាំកំណាត់ដើម: វិធីនេះគេអនុវត្តន៍ចំពោះដីចម្ការធំៗ និងពេលខ្លះអាចត្រូវចំណាយថវិកាច្រើន ។ ការដាំដុះតាមវិធីនេះគេអាចអនុវត្តន៍

បាននៅពេលដែលចម្ការមានដីសើមល្មម ។



វិធីនេះអាចចំណាយទុនតិច និងឆាប់រហ័សទៀតផង ប៉ុន្តែវាមានគុណវិបត្តិម្យ៉ាង គឺអាចបណ្តាលឱ្យដើមដុះមិនបានល្អក្នុងចម្ការពេលដែល ពុំមានភ្លៀងធ្លាក់គ្រប់គ្រាន់ ។

### ការត្រៀមពូជ

ជាទូទៅគេកាត់ពូជជាកង់ៗ មាន៣ ថ្នាំង និងភ្នែក៣ ល្អៗ ។ ដើមដែលជ្រើសរើសយកមកធ្វើជាពូជជាដើមដែលមានអាយុប្រមាណជា ៧ ខែ ទើបជាពូជដែលមានគុណភាពល្អ។ មិនត្រូវយកផ្នែកខាងគល់ពេក ឬ ចុងពេកមកធ្វើពូជឡើយ ម្យ៉ាងទៀត ជៀសវាងយកដើមណាស្គមហើយមានកើតជំងឺ។ កំណាត់ដើមអំពៅ ដែលគេយកមកធ្វើពូជដាំរួមមានៈ ថ្នាំង និងភ្នែក(ពន្លក) ៣ ល្អ ។







~ មុនពេលដាំគេត្រូវឆ្ងូតរង ឬ គន្លងដែលមាន ចន្លោះឃ្លាតពីគ្នា ០,៩០ ទៅ ១,២០ម ។ រួចហើយគេបោះពូជទៅបាតរង បន្ទាប់មកត្រូវរាស់លប់ ឬ ឆ្ងូតលប់តែម្តង ។

~ ក្នុងការបោះពូជគេអាចបោះកំណាត់ពូជនូវចន្លោះឃ្លាត ពីពូជមួយទៅពូជមួយ ឬពីគុម្ពមួយទៅគុម្ពមួយឃ្លាតពីគ្នាប្រមាណជា០,៥០ទៅ ០,៦០ម។



~ ការដាំក្នុងរណ្តៅ: ចំពោះការដាំក្នុងរណ្តៅ គឺគេដាក់ក្នុងមួយរណ្តៅពីរកំណាត់ពូជ ។ នៅបាតរណ្តៅគេដាក់ជីធម្មជាតិលាយជាមួយជី ១៥. ១៥.១៥ បន្តិចគឺប្រមាណជា៥០ ក្រាម ១៥.១៥.១៥ និង ជីធម្មជាតិប្រមាណជា០,៥ ទៅ ១គ.ក្រ ក្នុងមួយរណ្តៅ។ ចន្លោះឃ្លាតនៃរណ្តៅ ១ម x ០,៨ម និងទំហំ រណ្តៅ ៣៥ ស.ម បួនជ្រុងដែលមានជម្រៅប្រមាណជា៣០ ស.ម ការដាំ ដោយដាក់កំណាត់ដើមមានលក្ខណៈងាយស្រួលម្យ៉ាងគឺ យើងចំណាយទុនតិចពុំចាំបាច់ធ្វើការស្រោចស្រពហើយ



ដំណាំអាចដុះលូតលាស់បាន អាស្រ័យទៅដោយទឹកក្នុងដី និងទឹកភ្លៀង។

នៅប្រទេសកម្ពុជាយើងកសិករនិយមប្រមូលផលម្តងគត់។ រីឯនៅប្រទេសភាគច្រើនពេលដែលគេដាំលើចម្ការធំៗ គេដាំម្តងហើយគេអាចប្រមូលផលបានរហូតដល់៣ ទៅ ៤ ដង ក្នុងអំឡុងពេល ៥ ឆ្នាំ។ នៅប្រទេសជឿនលឿន ខ្លះទៀតមានចម្ការអំពៅដែលមានអាយុរហូតដល់ ១០ ទៅ ១៥ ឆ្នាំ ហើយគេអាចប្រមូលបានពី ៨ ទៅ ១២ ដង ។



## របៀបរៀបចំដីដាំ

តាមបទពិសោធន៍ជាក់ស្តែងរបស់កសិករ កែវ យ៉ិន រស់នៅភូមិទួលខ្ពស់ ខេត្តព្រៃវែង ដីដែលភ្ជួរហើយត្រូវកាប់បំផុស លើកជារងខ្ទង់អណ្តើក កម្ពស់ពីរតឹកទទឹងបីតឹកចំណែកឯបណ្តោយរងវិញអាស្រ័យតាមលទ្ធភាពដី។ យកស្លឹកឈើងាប់ ស្មៅងាប់ ចំបើងមកដុតបំពក់ រួចយកផេះ ដែលបានពីដុតនោះរោយតាមចន្លោះរង។ រងដាំអំពៅ តាមបទពិសោធន៍ កន្លងមកបើមិនដុតធ្វើឱ្យមានកណ្តៀរកើតឡើង។



បន្ទាប់ពីរៀបចំរងហើយយកកូនអំពៅមកតម្រៀបតាមចង្អូររង ដែលមានគម្លាត ៤ តឹកពីគុម្ពមួយទៅគុម្ពមួយ។





## ឃ. ការដាក់ជី

ដំណាំអំពៅជាដំណាំមួយប្រភេទដែលត្រូវការជីច្រើនគួរសមរូបមន្តជីក្នុង ១ហិកតា ៤៣-២០-៩៦)។ ក្នុងចំណោមជីជាតិចិញ្ចឹមសំខាន់ៗដំណាំអំពៅត្រូវការជីប៉ូតាស្យូម ច្រើនជាងគេ ព្រោះដំណាំអំពៅជាដំណាំមួយដែលបង្កើតជាតិស្ករ ។ បរិមាណនៃជាតិប៉ូតាស្យូមដែលត្រូវដាក់ស្មើរស្មើ នឹងជីអាហ្សូតដែរ។





ចំពោះលក្ខខណ្ឌប្រទេសកម្ពុជា យើងកសិករដាំមួយឆ្នាំតែម្តងទេ និងប្រមូលផលក៏តែម្តងដែរ ដូច្នេះ យើងអាចណែនាំឱ្យដាក់ជី ១៥. ១៥. ១៥ ប្រមាណ២០០ គ.ក្រ/ហ.ត។

បើករណីយើងដាំអំពៅសម្រាប់ធ្វើស្ករ យើងត្រូវដាក់ជីគីមី ១៥.១៥.

១៥ ក្នុងបរិមាណ ៤០០ គីឡូក្រាមក្នុងមួយហិកតា ដើម្បីធានាបានទិន្នផលស្ករច្រើនក្នុងមួយហិកតា ។

ការដាក់ជីលើដំណាំអំពៅជាទូទៅ គឺគេដាក់តែម្តងប៉ុណ្ណោះនៅពេលដាំ ហើយកម្រនឹងដាក់ជីអ៊ុយរ៉េបំប៉នម្តងទៀតណាស់ ព្រោះ អាចបណ្តាលឱ្យប៉ះពាល់ដល់ទិន្នផលស្ករ។ក្នុងករណី ចម្ការ ដែលយើងដាំម្តងហើយធ្វើការប្រមូលផលពី ២ ទៅ ៣ ដងនោះ ការដាក់ជីត្រូវដាក់ក្រោយពេលប្រមូលផល លើកទី ១ ជាថ្មីម្តងទៀតនូវបរិមាណជីដូចទៅនឹងការដាក់នៅពេលដាំ



ប៉ន្តែត្រូវបន្ថែមជីអ៊ុយរ៉េមួយកម្រិតថែមទៀតគឺប្រមាណពី៥០ ទៅ ១០០ គ.ក្រ/ហ.តដើម្បីជំនួយដល់ការដុះលូតលាស់របស់កូនអំពៅថ្មី ។

### ង. ការសំអាតស្មៅ

ការសំអាតស្មៅមានសារៈប្រយោជន៍ណាស់សម្រាប់ដំណាំអំពៅ។ការសំអាតស្មៅ គេត្រូវចាប់ផ្តើមអនុវត្តចាប់ពីពេលដែលយើងដាំរហូតដល់ដើមអំពៅមានស្លឹកធំជិតដីចម្ការ។ បើក្នុងចម្ការមានស្មៅតាំងពីពេលដាំរហូតដល់ ពេលអំពៅ



មានអាយុ៨៥ ថ្ងៃគឺអាចបណ្តាលឱ្យថយចុះទិន្នផលស្ករហូតដល់១២%បើធៀបទៅនឹងចម្ការ ដែលគ្មានស្មៅ។ ត្រូវពូនគល់ ដើម្បីជំនួយដល់ការដុះលូតលាស់នៃខ្នែងអំពៅ ដែលជាកត្តាមួយយ៉ាងសំខាន់ក្នុងការផ្តល់ទិន្នផល។

ការជម្រះស្មៅ គឺយើងអាចធ្វើដោយចបហើយចំពោះដីចម្ការធំ គេអាចធ្វើដោយដោយគ្រឿងយន្ត។

ចំពោះប្រទេសកម្ពុជាយើង ពេលដែលគេដាំនៅរដូវទឹកសម្រក ក្នុងខែវិច្ឆិកា ធ្នូជាដំបូងគេអាចជម្រះស្មៅមួយដង ឬ ពីរដងហើយរហូតដល់ពេលធ្លាក់ភ្លៀង ស្មៅដុះថ្មីទើបគេជម្រះម្តងទៀត។

## ៦. ជំងឺ និងសត្វល្អិតចង្រៃ

### ៦.១. សត្វល្អិតចង្រៃ:

សត្វចង្រៃមួយភាគធំគឺជាដង្កូវចោះកំពូល និងដើមអំពៅ រុយសហើយនឹងដង្កូវចោះដើម ។

#### ក. ដង្កូវស៊ីចោះកំពូល និងដើមអំពៅ :

នេះដោយបញ្ចូលទាំងដង្កូវស៊ីបំផ្លាញកំពូលនៅក្នុងដំណាក់កាលដំបូង (Chilo infuscatellus) ដង្កូវស៊ីចោះកំពូលមានក្បាលស (Scirpophaga exce-ptalis) ហើយ និងដង្កូវស៊ីចោះដើម (Sesamita inferens) ។





**វិធានការការពារ និងកំចាត់ :**

១. ប្រើប្រាស់ពូជធន់ដូចជាពូជ Uthong 3។

២. ប្រើប្រាស់ថ្នាំគីមីដូចជា Carbofuran 3% G (30-60 kg/ha)សម្រាប់ដំណាំអំពៅស្រោចស្រព។

Cypermethrin 3% W/V EC (13 ml/20លីត្រទឹក) ហើយនឹង Deltamethrin 3% W/V EC (10ml/20L) សម្រាប់ដំណាំអំពៅរដូវវស្សា ។




៣.ដាក់ពង្រាយកាកសំណល់ស្លឹកអំពៅ នៅចម្ការដើម្បីគ្របដណ្ដប់ដីក្រោយពេលប្រមូលផល ។

### ខ. រុយស (Aleurololus barodensis)





### ការការពារ និងកំចាត់ :

១. ដាក់ជីគីមីនៅក្នុងកម្រិត ៣០០គ្រាម/ហ.ត ការប្រើប្រាស់ថ្នាំគីមីពុលមិនជាការចាំបាច់ទេ។

២. សំអាតស្មៅចេញពីចម្ការអំពៅឱ្យស្អាតជាប្រចាំ ។

៣. នៅក្នុងករណីដែលរុយសកើតមានធ្ងន់ធ្ងរ អាចប្រើប្រាស់ថ្នាំគីមីបាញ់ទៅលើសត្វចង្រៃនោះរួមមាន: Dimethoate 40% W/V EC (40 ml/20L of water) or Carbofuran 20% W/V EC (50 ml/20L of water)។



គ. ដង្កូវស៊ីរូងដើម ( Dorysthenas bugueti )

វិធានការការពារ និងកំចាត់ :

១. រើសដង្កូវពី ១ លើក ទៅ ២ លើក មុនពេលធ្វើការដាំដុះ

២. ធ្វើការដាំឆ្លាស់ជាមួយមុខដំណាំដំឡូងមី ឬដំណាំម្នាស់

៣. ដាក់ថ្នាំ Endosulfan + BPMC 4.5% G ( 30 Kg/ha ) នៅតាមគន្លងនង្គ័លនៅពេលដាំដុះ ។




**៦.២. អំពីជំងឺ:**

រោគសញ្ញា និងវិធានការការពារ និងកំចាត់ជំងឺសំខាន់ត្រូវបានគេពិពណ៌នាដូចខាងក្រោម៖

ក. ជំងឺស្លឹកពណ៌ស ( phytoplasma ):

ជំងឺកើតដលែតងៃកើតមានលើដំណាំអំពៅមានលក្ខណ:ប្លែកៗ អាស្រ័យទៅនឹងការធ្វើរស្មីសំយោគនៃស្លឹក ។



វិធានការការពារ :

១- កាប់ដើមអំពៅដែលមានជំងឺចេញ ។

២- ប្រើប្រាស់ដើមអំពៅបណ្តុះដែលមិនមានជំងឺហើយ និងបានសំអាតជំងឺដោយដាក់ត្រាំនៅក្នុងទឹកក្តៅនៅសីតុណ្ហភាព ៥០អង្សាសេ សម្រាប់រយ:ពេល ២ ម៉ោង ឬជាការផ្លាស់ប្តូរដោយជីកកប់កង់អំពៅនៅក្នុងសារធាតុ Tetracycline HCI ( 500 ppm ) សម្រាប់រយ:ពេល ៣០ នាទីមុនពេលដាំដុះ ។

៣- ប្រើប្រាស់ពូជអំពៅដែលធន់ទ្រាំនឹងជំងឺ ឧទាហរណ៍:ពូជK88-102 ។

ខ. ជំងឺពន្លកស្មៅពណ៌បៃតង ( GGSD-phytoplasma ) :

ជំងឺនេះត្រូវបានស្គាល់ តាមលំដាប់ការកកើតស្លឹក ដូចស្មៅដែលមាន

ស្លឹកពណ៌បៃតងឆ្នូតចង្អៀត ឬពណ៌បៃតងខ្ចី។ គេអាចការពារនិងកំចាត់ដោយ :



១- កាប់ដើមអំពៅដែលមានជំងឺចេញ ។

២- ប្រើប្រាស់ដើមអំពៅបានសម្អាតជំងឺដោយដាក់ត្រាំនៅក្នុងទឹកក្តៅនៅសីតុណ្ហភាព ៥០ អង្សាសេ សម្រាប់រយៈពេល ២ ម៉ោង ឬ ជាការផ្លាស់ប្តូរដោយជីកកប់អំពៅនៅក្នុងសារធាតុ Tetracycline HCI ( 500 ppm ) សម្រាប់រយៈពេល៣០នាទីមុនពេលដាំដុះ ។

៣- ប្រើប្រាស់ពូជអំពៅដែលធន់ទ្រាំនឹងជំងឺ ឧទាហរណ៍: ពូជ Uthong 3។

### គ. ជំងឺស្នាមប្រឡាក់ ( Ustilago scitaminea ) :

រោគសញ្ញាគឺងាយចំណាំដោយមានលេចឡើងជាក់ស្តែង មានភាពរញ៉េរញ៉ៃដោយពេលខ្លះឃើញលេចឡើងនៅលើចុងឬនៅលើចុងកំពូលស្លឹក នៃដើមដែលទទួលរងការបំផ្លាញ ។



### វិធានការការពារ និងព្យាបាល :

១- ប្រើប្រាស់ពពួកពូជធន់នឹងជំងឺ ដូចជាពូជ Uthong 1, Uthong 2, Uthong 3, Uthong 4 ។

២- ប្រើប្រាស់សម្ភារដាំដុះដែលមិនមានជំងឺប្រភេទនេះ

៣- ដកចេញនូវកូនអំពៅ ឬដើមដែលមានជំងឺចេញពីចម្ការ ។

៤- ហើយនៅក្នុងករណីដែលចម្ការអំពៅ មិនទទួលរងការបំផ្លាញនៃជំងឺ ដើមអំពៅត្រូវដាក់ត្រាំទៅក្នុងថ្នាំផ្សិតដូចជា propiconazol 10% W/V EC (40ml/20L នៃទឹក) ឬ triadimefon 25% WP ( 50g/20L នៃទឹក ) រយ:ពេល ៣០ នាទី មុនពេលធ្វើការដាំដុះ ។




### ឃ. ជំងឺផ្កាស្រពោនរលួយពណ៌ក្រហម (Colletotrichum falcatum and Fusarium moniliforme) :

នៅក្នុងដំណាក់កាលដុះលូតលាស់ជាដំបូង រុក្ខជាតិប្រែពណ៌លឿង ។ ក្រោយរយ:ពេលពី ៥ ទៅ ៦ ខែ ដើមខ្នែងងាប់ ។ រោគសញ្ញាខាងក្នុងគឺចាប់ផ្តើមជាមួយនឹងការលួយជាលិកាពណ៌ក្រហម នៅក្នុងពេលជាមួយគ្នានោះដែរ អំពៅអាចប្រែពណ៌ទៅជាប្រផេះ និងវិវឌ្ឍទៅជាស្ដោត ស្ងួត ហើយប្រហោងក្នុង និងមានផ្ទុកទៅដោយសសៃមីសេល្យូម របស់ផ្សិត ហើយនឹងនៅពេលខ្លះ ជំងឺអាចរីករាលដាលពាសពេញផ្ទៃចម្ការទាំងមូលធ្វើឱ្យទិន្នផលអាចបាត់បង់រហូតដល់ ១០០ %ចំពោះដើមអំពៅនៅតូច ។ ជំងឺច្រើនកើតនៅលើដំណាំអំពៅដែលដាំដុះលើតំបន់ទំនាបដែលមិនសូវមានប្រព័ន្ធស្រោចស្រព ។





### វិធានការការពារ និងព្យាបាល:

១- ប្រើប្រាស់ពូជធន់នឹងជំងឺដូចជាពូជ K84-200, K88-92, K90-54, K90-77

and Uthong 3

២- ដកចេញនូវដើមដែលមានជំងឺចេញពីចម្ការ

៣- ធ្វើការដាំដំណាំឆ្លាស់

៤- ធ្វើការហាលដីឱ្យបាន ៣ ខែ

៥- ប្រើប្រាស់ដើមអំពៅពូជដែលមិនមានជំងឺបំផ្លាញ

៦- ប្រើប្រាស់ថ្នាំផ្សិតដូចជា : benomyl 50% WP ( 15g/20L នៃទឹក ) thiabendazol 90% WP ( 15g/20L នៃទឹក ) សម្រាប់ដាក់ត្រាំកំណាត់ដើមអំពៅពូជ ។




## ៥. ការប្រមូលផល

ការប្រមូលផលដំណាំអំពៅនៅប្រទេសកម្ពុជាយើង គឺគេអាចធ្វើឡើងដោយយោងតាមលក្ខខណ្ឌ អាកាសធាតុនិងទីផ្សារ ប៉ុន្តែជាទូទៅ គេប្រមូលផល ពេលដែលគេដាំដំណាំមានអាយុប្រមាណជា១០ទៅ ១៣ខែបន្ទាប់ពីដាំ។ ចំពោះការដាំអំពៅសម្រាប់គ្រាន់តែលក់ដើម្បីគៀបទឹកហូប ការប្រមូលផលពុំសូវមានបញ្ហាអ្វីចោទឡើងទេ គឺគេអាចប្រមូលផលក្នុងអំឡុងខែកញ្ញាគឺពេលអំពៅមានអាយុ ១០ ខែមុនពេលទឹកលិចអំពៅសម្រាប់ធ្វើស្ករ ពេលវេលានៃការប្រមូលផលគឺក្នុងអំឡុងពេលខែធ្នូ ឬមករា



ព្រោះត្រឹមខែនេះអំពៅមានអាយុពី ១២ ទៅ ១៣ ខែ និងជាពេលដែលអាកាសធាតុត្រជាក់ ហើយអំពៅមានជាតិស្ករច្រើន ។

ការប្រមូលផលនៅចម្ការធំៗ ជួនកាលគេដុតចម្ការជាមុនសិនទើបគេកាប់ដើមអំពៅក្នុងករណីនេះ គេត្រូវកាប់អំពៅភ្លាម និងប្រញាប់យកទៅរោងចក្រ ព្រោះបើទុកចោលលើសពី ៣ ថ្ងៃអាចបណ្ដាលឱ្យខូចគុណភាពស្ករ។













# ៦. ការកែច្នៃ

## វិធីផលិតទឹកខ្មេះពីទឹកអំពៅ

បច្ចុប្បន្ននេះប្រជាពលរដ្ឋខ្មែរយើង ដែលរស់នៅតាមទីជនបទបានប្រើប្រាស់ទឹកត្នោតមកធ្វើជាទឹកខ្មេះ អ្នកខ្លះទៀតបានប្រើចេកទុំ ក្រៅពីនោះ គឺគេទិញទឹកខ្មេះដែលមានលក់ស្រាប់ច្រកដាក់ក្នុងដបមកពីផ្សារ។ តាមការពិតទឹកខ្មេះអាចត្រូវបានធ្វើដោយវត្ថុធាតុដើមច្រើនយ៉ាងណាស់ ក្នុងនោះក៏មានទឹកអំពៅផងដែរ ចំណែកឯវិធីនៃការធ្វើវិញ គឺមានច្រើនយ៉ាងខុសៗគ្នាដែរ ចំពោះរសជាតិដែលយើងទទួលបានវិញក៏មិនដូចគ្នាដែរ ៕









# ឯកសារយោង


១. សៀវភៅតូចដំណាំអំពៅនាយកដ្ឋានក្សេត្រសាស្ត្រខែកញ្ញា, ១៩៩៤

២. សៀវភៅតូចដំណាំអំពៅនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម លេខ១៤៤៥-CAM, (SF)ឆ្នាំ២០០៥

៣. សៀវភៅបទពិសោធន៍កសិករដាំអំពៅ,២០១៤


